**EMBASSY OF JAPAN IN CAMBODIA**

# PRESS RELEASE

No. 23PR-25/EoJ 20 May 2025

## Japan Provides US$1,182,658 for Developing Quality Physical Education Teacher, and Supporting Children and Youth

The Government of Japan will provide US$1,182,658 in total for two recipient organizations under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the recipients, to carry out the following projects:

1. ‘Project on Developing 4-year Quality Physical Education Teacher Education University through Utilizing ICT (Year 3)’
(US$618,086)
Recipient: Non-Profit Organization HEARTS OF GOLD (HoG)

In this project, HoG will implement activities to improve the management system of the university, such as library, international center, internal quality assurance, teacher development, student management, alumni support and security management in National Institute of Physical Education and Sport (NIPES) by utilizing ICT. This project aims to establish sustainable management structure in order to train teachers of physical education fitted with “Minimum Standards for Accreditation of Higher Education Institutions(MSAHEI)” in Cambodia.

2. ‘Children and Youth Support by Expanding Access to Lifelong Learning Center (LLLC) in Banteay Meanchey Province, Cambodia(Year 3)’
(US$564,572)
Recipient: Kokkyo naki Kodomotachi (KnK)

In this project, KnK will continue to support youth, especially those who suffer from unstable jobs, lack of living skills, and dropping out of schools. For the first and second year of this project, three new LLLCs were constructed. For the third year, two new LLLCs will be constructed and equipped with learning materials. By providing equivalency education class and enhanced vocational training as well as close support to children and youth, they can acquire skills which helps them to create a foundation for a better life in their future.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided nearly US$60 million for over 160 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---

*Embassy of Japan in Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា**

**សេចក្តីប្រកាសព័ត៌មាន**

លេខ. 23PR-25/EoJ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥

**ជប៉ុនផ្តល់ថវិកា ១,១៨២,៦៥៨ ដុល្លារអាមេរិក**

**សម្រាប់ការអភិវឌ្ឍគ្រូបង្រៀនអប់រំកាយដែលមានគុណភាព និងការជួយកុមារ និងយុវជន**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **១,១៨២,៦៥៨ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនពីរក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញ សមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងស្ថាប័នទទួលជំនួយ សម្រាប់អនុវត្តគម្រោងដូចតទៅ៖

**១. "គម្រោងអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាអប់រំគ្រូបង្រៀនអប់រំកាយដែលមានគុណភាពរយៈពេលបួនឆ្នាំ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ឆ្នាំទី៣)" (ថវិកាចំនួន ៦១៨,០៨៦ ដុល្លារអាមេរិក)**

**ស្ថាប័នទទួលជំនួយ៖ អង្គការក្រៅរដ្ឋាភិបាល បេះដូងមាស (HoG)**

នៅក្នុងគម្រោងនេះ អង្គការក្រៅរដ្ឋាភិបាល បេះដូងមាស នឹងអនុវត្តសកម្មភាពមួយចំនួន ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានឧត្តមសិក្សា ដូចជា បណ្ណាល័យ មជ្ឈមណ្ឌលអន្តរជាតិ ការធានាគុណភាពផ្ទៃក្នុង ការអភិវឌ្ឍគ្រូបង្រៀន ការគ្រប់គ្រងនិស្សិត ការគាំទ្រអតីតនិស្សិត និងការគ្រប់គ្រងសន្តិសុខ នៅក្នុងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា (NIPES ) ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ គម្រោងនេះមានគោលបំណងបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយនិរន្តរភាព ដែលរួមចំណែកក្នុងការអភិវឌ្ឍគ្រូបង្រៀនអប់រំកាយប្រកបដោយគុណភាព ស្របតាម "ស្តង់ដាគុណភាពអប្បបរមាសម្រាប់ការផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា (MSAHEI)" នៅក្នុងប្រទេសកម្ពុជា។

## ២. “ការជួយកុមារ និងយុវជន ដោយការពង្រីកលទ្ធភាពទទួលបានមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត (LLLC) ក្នុងខេត្តបន្ទាយមានជ័យ” (ថវិកាចំនួន ៥៦៤,៥៧២ ដុល្លារអាមេរិក)

## ស្ថាប័នទទួលជំនួយ៖ អង្គការកុមារឥតព្រំដែន

នៅក្នុងគម្រោងនេះ អង្គការកុមារឥតព្រំដែន នឹងបន្តគាំទ្រដល់យុវជន ជាពិសេសអ្នកដែលទទួលរងការលំបាកដោយសារការងារមិនស្ថិតស្ថេរ ខ្វះជំនាញជីវិត និងបោះបង់ការសិក្សា។ សម្រាប់ឆ្នាំទីមួយ និងទីពីរនៃគម្រោងនេះ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតថ្មីចំនួនបី ត្រូវបានសាងសង់។ សម្រាប់ឆ្នាំទីបី មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតថ្មីចំនួនពីរ នឹងត្រូវបានសាងសង់ និងបំពាក់ដោយសម្ភារៈសិក្សា។ តាមរយៈការផ្តល់ថ្នាក់អប់រំសមមូល និងបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាការគាំទ្រយ៉ាងជិតស្និទ្ធដល់កុមារ និងយុវជន ពួកគេអាចទទួលបានជំនាញ ដែលជួយពួកគេបង្កើតមូលដ្ឋានគ្រឹះសម្រាប់ជីវិតកាន់តែប្រសើរនាពេលអនាគត។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៦០លានដុល្លារអាមេរិក ដល់គម្រោងចំនួន ១៦០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---


ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១

អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp

គេហទំព័រ៖ http://www.kh.emb-japan.go.jp

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា**
**ផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន**
**ថ្ងៃអង្គារ ទី២០ ខែឧសភា ឆ្នាំ២០២៥**

**គម្រោងអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាអប់រំគ្រូបង្រៀនអប់រំកាយដែលមានគុណភាពរយៈពេលបួនឆ្នាំ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ឆ្នាំទី៣)**
**អង្គការក្រៅរដ្ឋាភិបាល បេះដូងមាស (HoG)**

**ការជួយកុមារ និងយុវជន ដោយការពង្រីកលទ្ធភាពទទួលបានមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត (LLLC) ក្នុងខេត្តបន្ទាយមានជ័យ**
**អង្គការកុមារឥតព្រំដែន (KnK)**

- សូមគោរព **លោកស្រី យ៉ូណេយ៉ាម៉ា ហារុកា** ប្រធានអង្គការបេះដូងមាសប្រចាំអាស៊ីអាគ្នេយ៍
- សូមគោរព **លោក ស្រី  សាកាន** នាយកប្រចាំប្រទេស នៃអង្គការកុមារឥតព្រំដែន
- លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនចំនួន២ នាថ្ងៃនេះ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា "អ៊ិនវ៉េន" បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៦០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពីគម្រោងចំនួនពីរ ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ៖

រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាប្រមាណ ៦១៨,០៨៦ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល បេះដូងមាស (HoG)។

ចាប់តាំងពីឆ្នាំ២០១៩មក អង្គការក្រៅរដ្ឋាភិបាលបេះដូងមាស បាននិងកំពុងអនុវត្តគម្រោងតាមរយៈជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា (NIPES)៖ ដែលជាគ្រឹះស្ថានបណ្តុះបណ្តាលតែមួយគត់សម្រាប់គ្រូបង្រៀនអប់រំកាយ ដើម្បីក្លាយជាសាកលវិទ្យាល័យ ដែលមានរយៈពេលបណ្តុះបណ្តាលបួនឆ្នាំ។ នៅក្នុងគម្រោងនេះ អង្គការក្រៅរដ្ឋាភិបាលបេះដូងមាស នឹងអនុវត្តសកម្មភាពមួយចំនួន ដើម្បីដោះស្រាយនូវឧបសគ្គទាំងប្រាំពីរ ក្នុងការគ្រប់គ្រងសម្រាប់សាកលវិទ្យាល័យ ដែលមានដូចជា បណ្ណាល័យ មជ្ឈមណ្ឌលអន្តរជាតិ ការធានាគុណភាពផ្ទៃក្នុង ការអភិវឌ្ឍគ្រូបង្រៀន ការគ្រប់គ្រងនិស្សិត ការគាំទ្រអតីតនិស្សិត និងការគ្រប់គ្រងសន្តិសុខ នៅក្នុងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា (NIPES ) ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ តាមរយៈសកម្មភាពទាំងនេះ ខ្ញុំសង្ឃឹមថានឹងមានរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយនិរន្តរភាពសម្រាប់ការកសាងប្រព័ន្ធ ធនធានមនុស្ស និងបរិក្ខារ ក៏ដូចជាបង្កើតប្រព័ន្ធប្រកបដោយនិរន្តរភាព ដើម្បីនាំមកនូវគ្រូអប់រំកាយប្រកបដោយគុណភាពសម្រាប់វិទ្យាល័យ និងអនុវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា។

បន្ទាប់មក រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាប្រមាណ ៥៦៤,៥៧២ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការកុមារឥតព្រំដែន។

ចាប់តាំងពីឆ្នាំ២០០០មក Kokkyo naki Kodomotachi បាននិងកំពុងអនុវត្តគម្រោង ហើយពួកគេអនុវត្តគម្រោងដែលជួយគាំទ្រការងារតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនក្នុងខេត្តបន្ទាយមានជ័យ ដែលនៅក្បែរទីតាំងមូលដ្ឋានរបស់ពួកគេក្នុងខេត្តបាត់ដំបង។ នៅក្នុងគម្រោងនេះ អង្គការកុមារឥតព្រំដែន នឹងបន្តគាំទ្រដល់យុវជន ជាពិសេសអ្នកដែលទទួលរងការលំបាកដោយសារការងារមិនស្ថិតស្ថេរ ខ្វះជំនាញជីវិត និងបោះបង់ការសិក្សា។ សម្រាប់ឆ្នាំទីមួយ និងទីពីរនៃគម្រោងនេះ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតថ្មីចំនួនបី ត្រូវបានសាងសង់។ សម្រាប់ឆ្នាំទីបី មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតថ្មីចំនួនពីរទៀត នឹងត្រូវបានសាងសង់ និងបំពាក់ដោយសម្ភារៈសិក្សា។ តាមរយៈការផ្តល់ថ្នាក់អប់រំសមមូល និងបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាការគាំទ្រយ៉ាងជិតស្និទ្ធដល់កុមារ និងយុវជន ពួកគេអាចទទួលបានជំនាញ ដែលជួយពួកគេបង្កើតមូលដ្ឋានគ្រឹះសម្រាប់ជីវិតកាន់តែប្រសើរនាពេល អនាគត។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន ដែលរួមមានមិនត្រឹមតែក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈប៉ុណ្ណោះទេ ថែមទាំងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍សង្គម រួមទាំងបរិស្ថានផងដែរ។ រដ្ឋាភិបាលជប៉ុន នឹងចូលរួមចំណែកដោះស្រាយបញ្ហានានា ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិរបស់ជប៉ុន។

ជាទីបញ្ចប់នៃការថ្លែងសន្ទរកថារបស់ខ្ញុំ ខ្ញុំសូមឱ្យគម្រោងទាំង២ ដែលចុះហត្ថលេខានាថ្ងៃនេះ ដំណើរការទៅដោយរលូន និងទទួលបានភាពជោគជ័យនាពេលអនាគត។ ហើយខ្ញុំសូមជូនពរ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជា កាន់តែរីកចម្រើន។

សូមអរគុណច្រើន។